# តំណាងខ្មែរក្រោមសង្ឃឹមលើស្ថានទូតអាមេរិក នៅភ្នំពេញជួយពលរដ្ឋខ្មែរនៅកម្ពុជាក្រោម

KMS News October 04 08



ប្រតិភូខ្មែរកម្ពុជាក្រោមពេលចូលជួបមន្ត្រីស្ថានទូតអាមេរិកប្រចាំកម្ពុជា



អតីតព្រះសង្ឃខ្មែរក្រោមត្រូវបានអាជ្ញាធរយួនចាប់ផ្សឹក និងយកទៅកាត់ទោស

ដោយ : សច្ចះ

មន្ត្រីស្ថានទូតអាមេរិក ប្រចាំក្រុងភ្នំពេញ បានទទួលយកសំណើធ្វើអន្តរាគមន៍ពីតំណាងបងប្អូនខ្មែរកម្ពុជាក្រោមជាផ្លូវការហើយ ដើម្បីធ្វើយ៉ាងណាស្នើអាជ្ញាធរក្រុងហាណូយ ប្រទេសយួន ផ្តល់សិទ្ធិសេរីភាពសាសនា ដល់ពលរដ្ឋខ្មែរ នៅកម្ពុជាក្រោម ពិសេសស្នើទៅរដ្ឋាភិបាលយួន ដោះលែងព្រះ

តទៅទំព័រ៤ ន

តមកពីទំព័រ១ ន

សង្ឃ ដែលអាជ្ញាធរយួន បានចាប់ផ្សឹក ហើយដាក់ពន្ធនាគារកាលពីឆ្នាំមុន ។

កាលពីល្ងាចថ្ងៃទី២ខែតុលាឆ្នាំ២០០៨ តំណាងបងប្អូនខ្មែរកម្ពុជាក្រោម មកពីសមាគមនិងអង្គការសិទ្ធិមនុស្ស ចំនួន៤ផ្សេងៗពីគ្នា ទៅជួបជាមួយនឹងអ្នកស្រីភារៈធារី ស្ថានទូតសហរដ្ឋអាមេរិក ប្រចាំទីក្រុងភ្នំពេញ ។ ក្នុងនោះមានលោក *ថាច់ សេដ្ឋា* ជាប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាមន្ត្រីជាន់ខ្ពស់ គណបក្សសមរង្ស៊ី, លោក*យន្ត ថារ៉ូ* ប្រធានក្រុមប្រឹក្សាភិបាល អង្គការស្ត្រីខ្មែរកម្ពុជាក្រោម, ជាប្រធានក្រុមប្រឹក្សាភិបាលមូលនិធិខ្មែរសម្រាប់អ្នកក្រីក្រ និងជាអ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ី មណ្ឌលបន្ទាយមានជ័យ, លោក*អាង ច័ន្ទរិទ្ធិ* ប្រធានអង្គការ ការពារសិទ្ធិមនុស្ស ខ្មែរកម្ពុជាក្រោម, ព្រះតេជគុណ *យឿង សិន* ប្រធានសមាគមខ្មែរកម្ពុជាក្រោម, អ្នកស្រី *ព្រំ យ៉ាង* ប្រធានអង្គការស្ត្រីខ្មែរកម្ពុជាក្រោម ព្រមទាំងសហការីមួយចំនួនទៀត ។

លោក*យន្ត ថារ៉ូ* បានមានប្រសាសន៍ ប្រាប់ *ខ្មែរម្ចាស់ស្រុក* អំពីលទ្ធផល ក្រោយពីការជួបជាមួយមន្ត្រី ស្ថានទូតអាមេរិក យ៉ាងដូច្នេះថា "*យើងខ្ញុំ ជាតំណាងបងប្អូនខ្មែរកម្ពុជាក្រោម បានទៅជួប មន្ត្រីស្ថានទូតអាមេរិកាំងកាលពីល្ងាចម្សិលមិញ (០២ តុលា ២០០៨) ។ កាលពីយើងសរសេរលិខិត ស្នើសុំជួបឧបការី រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកាំង... ក៏ប៉ុន្តែដោយសារលោកឧបការី អត់មានពេល ទើបមន្ត្រីស្ថានទូតអនុញ្ញាត ឱ្យពួកយើងជួបកាលពីល្ងាចម្សិលមិញ ថ្ងៃទី២ ខែតុលានេះ ។ ការជួបជាមួយនឹងមន្ត្រីស្ថានទូតនោះ យើងលើកឡើង អំពីករណី បងប្អូនខ្មែរកម្ពុជាក្រោម ដែលរស់នៅទឹកដីកម្ពុជាក្រោម ហៅថាវៀតណាមខាងត្បូងកំពុងជួបប្រទះការរំលោភសិទ្ធិមនុស្ស ដូចជាការចាប់ព្រះសង្ឃ ទាំង៥ព្រះអង្គដាក់ពន្ធនាគារ, ហើយស្ត្រីខ្មែរកម្ពុជាក្រោម២នាក់ នៅខេត្តឃ្លាំង អំពីការទាមទារនូវសិទ្ធិសេរីភាព និងសិទ្ធិដីធ្លី ត្រូវអាជ្ញាធរវៀតណាម ចាប់ដាក់ពន្ធនាគារនិងស្ថានភាពជាច្រើនទៀត*" ។

លោក*យន្ត ថារ៉ូ* បានបន្តថា គណៈប្រតិភូខ្មែរ កម្ពុជាក្រោម ក៏បានប្រាប់មន្ត្រី ស្ថានទូតអាមេរិក អំពីករណីដែលបានកើតមានកន្លងមក នៅទឹកដីកម្ពុជាក្រោម ដូចជាការបំភិតបំភ័យ, ការរឹតត្បិតផ្នែកជំនឿសាសនា និងការបញ្ចេញមតិ ។ លោកបានថ្លែងទៀតថា ការជួបជាមួយមន្ត្រីស្ថានទូតអាមេរិក នាពេលនោះបានផ្តោតសំខាន់ទៅលើ ការស្នើសុំឱ្យមន្ត្រីស្ថានទូតអាមេរិក នៅក្រុងភ្នំពេញជួយធ្វើអន្តរាគមន៍ ។ ជាមួយគ្នានោះដែរ គណៈប្រតិភូ ក៏បានលើកឡើងករណីអតីតចៅអធិការវត្តភ្នំដិនខាងជើង ក្នុងខេត្តតាកែវ *ទីម សាខន* ដែលសព្វថ្ងៃរដ្ឋាភិបាលវៀតណាម ចេញលិខិតជាផ្លូវការ ដោះលែងឱ្យចេញពីពន្ធនាគារហើយ បែរជាមិនអនុញ្ញាត ឱ្យលោកវិលត្រឡប់ចូលមកកម្ពុជាវិញនិងបានគំរាម បង្ខំឱ្យលោកធ្វើលិខិតសុំការរស់នៅ ជាជនជាតិវៀតណាមរៀបការប្រពន្ធ និងសុំដីធ្លីពីអាជ្ញាធរវៀតណាម ។

លោក*យន្ត ថារ៉ូ* បានអោយដឹងទៀតថាទង្វើរបស់អាជ្ញាធរវៀតណាមនោះ ជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ។ ដូច្នេះហើយ បានជាពួកលោកទាំងអស់គ្នា ជាតំណាងឱ្យបងប្អូនខ្មែរកម្ពុជាក្រោម មកពីស្ថាប័នចំនួន៤ផ្សេងគ្នា ស្នើស្ថានទូតអាមេរិកប្រចាំក្រុងភ្នំពេញ ឱ្យជួយធ្វើអន្តរាគមន៍ និងបានដឹងអំពីស្ថានភាពទាំងអស់គ្នា ។

ក្នុងជំនួប ដែលបានចំណាយពេលរាប់ម៉ោងនោះ មន្ត្រីស្ថានទូតអាមេរិក បានប្រាប់គណៈប្រតិភូ ជាតំណាងបងប្អូនខ្មែរកម្ពុជាក្រោមថា កិច្ចការទាំងអស់នេះ ស្ថានទូតអាមេរិកប្រចាំក្រុងភ្នំពេញ មិនអាចជួយដោយផ្ទាល់បានទេ ។ ប៉ុន្តែអាចយកព័ត៌មានទាំងអស់នេះ ទៅរាយការណ៍ ទៅរដ្ឋាភិបាលអាមេរិក ក៏ដូចជាស្ថានទូត សហរដ្ឋអាមេរិក ប្រចាំការនៅអង្គការសិទ្ធិមនុស្សអាស៊ាន និងប៉ាស៊ីហ្វិក ។ មន្ត្រីស្ថានទូតអាមេរិក បានប្រាប់គណៈប្រតិភូខ្មែរកម្ពុជាក្រោមទៀតថា ហេតុការណ៍ទាំងអស់នោះ បានកើតឡើង នៅប្រទេសវៀតណាម, ហើយបើព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជាគាត់អាចជួយធ្វើអន្តរាគមន៍បាន ។ តែទោះជាយ៉ាងណា ស្ថានទូតអាមេរិក នៅតែសង្ឃឹម និងខិតខំប្រឹងប្រែងជម្រុញអោយរដ្ឋាភិបាលក្រុងហាណូយ គោរពដល់សិទ្ធិ បងប្អូនខ្មែរកម្ពុជាក្រោម ។ ម៉្យាងទៀតមន្ត្រីស្ថានទូតអាមេរិកាំង ប្រចាំទីក្រុងភ្នំពេញសន្យាថានាពេលឆាប់ៗខាងមុខនេះ ស្ថានទូតអាមេរិក នឹងអនុញ្ញាត ឱ្យគណៈប្រតិភូបងប្អូនខ្មែរកម្ពុជាក្រោម ជួបមន្ត្រីស្ថានទូតម្តងទៀត ដើម្បីនិយាយគ្នាពីបងប្អូនខ្មែរកម្ពុជាក្រោមនៅកម្ពុជា ហើយគ្រោងនឹងលើកឡើង អំពីការរំលោភសិទ្ធិមនុស្ស មកលើបងប្អូនខ្មែរកម្ពុជាក្រោម ។

លោក*យន្ត ថារ៉ូ* បានថ្លែងអំពីក្តីសង្ឃឹមថាបងប្អូនខ្មែរនៅកម្ពុជាក្រោម នឹងទទួលបាននូវការធ្វើអន្តរាគមន៍ ពីស្ថានទូតអាមេរិកនៅក្រុងភ្នំពេញ ធ្វើយ៉ាងណា ឱ្យបងប្អូនខ្មែរកម្ពុជាក្រោមទទួលបានសិទ្ធិសេរីភាព សិទ្ធិសាសនា ។ លោកបានថ្លែងយ៉ាងដូច្នេះថា "*យើងមានការសង្ឃឹមច្រើន ដោយសារស្ថានទូតអាមេរិក ជាស្ថានទូតមួយនៃប្រទេសមហាអំណាច នៅលើពិភពលោក, ហើយបើកាលណាគេសន្យាច្បាស់ជាគេធ្វើជាមិនខាន ប៉ុន្តែគ្រាន់តែថា វា យូរឬឆាប់ប៉ុណ្ណោះ*" ៕

KMS October 04 2008